ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

********

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

ឃ្ល.ក/លេខ ០៦.០៤៧/១៣ គ.ជ.ប.អគ្គ.ពស

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ២០១៣

# ទឹកខ្មៅលុបលាងមិនជ្រះចំនួន ៤០,០០០ដប ជាជំនួយរបស់ប្រទេសឥណ្ឌា

សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥នេះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) បានទទួលជំនួយទឹកខ្មៅលុបលាងមិនជ្រះចំនួន ៤០,០០០ដប ដែលមានតម្លៃជាទឹកប្រាក់សរុប ៨៧៧,៨៧៤ដុល្លារសហរដ្ឋអាមេរិក ដែលជាជំនួយឧបត្ថម្ភរបស់សាធារណរដ្ឋឥណ្ឌា ។ តម្លៃទឹកខ្មៅនេះគឺជាតម្លៃសរុបរួមទាំងការដឹកជញ្ជូន និងការធានារ៉ាប់រង ។

ទឹកខ្មៅលុបលាងមិនជ្រះនេះ មួយដបមានចំណុះ ៧០សេសេ(CC) ហើយបានដឹកមកដល់ឃ្លាំង គ.ជ.ប កាលពីសប្តាហ៍មុន ។ នៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣ វេលាម៉ោង ៨:៣០ព្រឹក គ.ជ.ប បានរៀបចំពិធីប្រគល់និងទទួលទឹកខ្មៅលុបលាងមិនជ្រះនៅទីស្តីការ គ.ជ.ប ។

ពិធីប្រគល់ និងទទួលទឹកខ្មៅខាងលើ បានធ្វើឡើងរវាងឯកឧត្តម អ៊ឹម សួស្តី ប្រធាន គ.ជ.ប និងឯកឧត្តម ឌីណេស ប៉ាតណៃក (Dinesk K. Patnaik) ឯកអគ្គរដ្ឋទូតសាធារណរដ្ឋឥណ្ឌាប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ។

ឯកឧត្តម ទេព នីថា អគ្គលេខាធិការ គ.ជ.ប បានមានប្រសាសន៍ថា សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ មានការិយាល័យបោះឆ្នោតចំនួន ១៩.០០៩ ការិយាល័យ ហើយក្នុងមួយការិយាល័យត្រូវប្រើប្រាស់ទឹកខ្មៅលុបលាងមិនជ្រះចំនួន ២ដប ។ ទឹកខ្មៅទាំងនេះ មួយចំនួនត្រូវទុកបម្រុងនៅ គ.ជ.ប និងនៅគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត(គធ/ខប) ។៚